**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**ក្រសួងមហាផ្ទៃ**

លេខ: ៣៦៥ ប្រក

# ប្រកាស

## ស្តីពី

## ការបង្កើតគណៈកម្មការកំណែទម្រង់មន្ត្រីរដ្ឋបាលស៊ីវិល និងមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធនាគារ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៧៥ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០០/០៩៦ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌលេខាធិការរដ្ឋបាលក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៣/៨៩២ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៣ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៧៣ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមការចាំបាច់របស់ក្រសួងមហាផ្ទៃ

# សម្រេច

**ប្រការ ១.-**

បង្កើតគណៈកម្មការកំណែទម្រង់មន្ត្រីរដ្ឋបាលស៊ីវិល និងមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** | | ប្រធាន |
| ២. ឯកឧត្តម **សក់ សេដ្ឋា** | រដ្ឋលេខាធិការប្រចាំការក្រសួងមហាផ្ទៃ | អនុប្រធានទី១ |
| ៣. ឯកឧត្តម **លេង ធី** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធានអចិន្ត្រៃយ៍ |
| ៤. ឯកឧត្តម **ប៉ាច ហាមថាន** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៥. ឯកឧត្តម **ឌី ច័ន្ទផល** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៦. លោកជំទាវ **ជុំ ម៉ុនអេង** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិកា |
| ៧. ឯកឧត្តម **ម៉ុន ហុន** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៨. ឯកឧត្តម **អេង មង្គល** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៩. ឯកឧត្តម **ម៉ាន់ ចំរើន** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប | សមាជិក |
| ១០. ឯកឧត្តម សន្តិបណ្ឌិត **ខៀវ សុភ័គ** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ១១. ឯកឧត្តម សន្តិបណ្ឌិត **ម៉ៅ ច័ន្ទតារា** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ១២. ឯកឧត្តម **កៅ ខុនជាវ៉ា** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ១៣. ឯកឧត្តម **ឡាំ ជា** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ១៤. ឯកឧត្តម **គុល ចិរគៀ** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ១៥. ឯកឧត្តម **អ៊ុង សាមី** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ១៦. ឯកឧត្តម **ប្រាក់ សំអឿន** | អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល | សមាជិក |
| ១៧. ឯកឧត្តម នាយឧត្តមសេនីយ៍ **ប៉ោ គត្តិ** | អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន | សមាជិក |
| ១៨. ឯកឧត្តម **អ៊ុំ ឈាង** | អគ្គាធិការ នៃអគ្គាធិការដ្ឋាន | សមាជិក |
| ១៩. ឯកឧត្តម នាយឧត្តមសេនីយ៍ **គង សុខន** | អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម | សមាជិក |
| ២០. ឯកឧត្តម នាយឧត្តមសេនីយ៍ **សេង យុវិតន់** | អគ្គនាយក នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ | សមាជិក |
| ២១. ឯកឧត្តម នាយឧត្តមសេនីយ៍ **ចឹម សុផា** | អគ្គនាយក នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង | សមាជិក |
| ២២. ឯកឧត្តម **អ៊ុច ចាន់ណារ៉ា** | ប្រធានក្រុមប្រឹក្សានីតិកម្ម | សមាជិក |
| ២៣. ឯកឧត្តម ឧត្តមអគ្គានុរក្សថ្នាក់លេខ១ **ឆែម សាធុច** | អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធនាគារ | សមាជិក |
| ២៤. ឯកឧត្តម នាយឧត្តមសេនីយ៍ **មាស ចិរិទ្ធ** | អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ | សមាជិក |
| ២៥. លោកឧត្តមសេនីយ៍ទោ **ញ៉ែម ម៉ាន់នី** | ប្រធានស្តីទីលេខាធិការដ្ឋាន គ.ជ.ប.ទ | សមាជិក |
| ២៦. ឯកឧត្តម **អ៊ុង ចន្ធី** | អគ្គនាយករង និងជាប្រធាននាយកដ្ឋានបុគ្គលិក | សមាជិក។ |

**ប្រការ ២.-**

គណៈកម្មការនេះ មានភារកិច្ចដូចខាងក្រោម៖

- សិក្សា ស្រាវជ្រាវគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា សម្រាប់ធ្វើការវិភាគមុខងារ រចនាសម្ព័ន្ធ នៃអង្គភាពនីមួយៗ ដើម្បីកំណត់មុខងារ និងរៀបចំរចនាសម្ព័ន្ធឡើងវិញ កំណត់ក្របខ័ណ្ឌ ឋានន្តរស័ក្តិ ការបំពាក់មធ្យោបាយសម្ភារៈបម្រើការងារ និងការបណ្តុះបណ្តាលកសាងសមត្ថភាពធនធានមនុស្ស សំដៅធ្វើការកែទម្រង់មន្ត្រីរដ្ឋបាលស៊ីវិលនៅថ្នាក់ក្រសួងមហាផ្ទៃ និងមន្ត្រីពន្ធនាគារ សម្រាប់រយៈពេលចំពោះមុខ និងរយៈពេលមធ្យម ទៅរយៈពេលវែងស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល

- ពិនិត្យ សិក្សាលើច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលមានជាធរមាន ដើម្បីធ្វើវិសោធនកម្ម ឬរៀបចំច្បាប់ លិខិតបទដ្ឋានគតិយុត្តថ្មីៗបន្ថែមទៀត សំដៅបម្រើដល់ការងារកំណែទម្រង់មន្ត្រីរដ្ឋបាលស៊ីវិលនៅថ្នាក់ក្រសួងមហាផ្ទៃ និងមន្ត្រីពន្ធនាគារ
- ពិនិត្យរៀបចំឯកសារពាក់ព័ន្ធការងារកំណែទម្រង់មន្ត្រីរដ្ឋបាលស៊ីវិលនៅថ្នាក់ក្រសួងមហាផ្ទៃ និងមន្ត្រីពន្ធនាគារ ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច
- បំពេញភារកិច្ចផ្សេងៗទៀតតាមការចាំបាច់។

**ប្រការ ៣.-**

គណៈកម្មការនេះអាចបង្កើតក្រុមការងារ និងមានសិទ្ធប្រើប្រាស់មន្ត្រីក្រោមឱវាទរបស់ខ្លួនដើម្បីជួយការងារតាមការចាំបាច់។

**ប្រការ ៤.-**

អនុប្រធាន សមាជិក សមាជិកា ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ។

**ប្រការ ៥.-**

អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយក នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ អគ្គាធិការ នៃអគ្គាធិការដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គនាយក នៃអគ្គនាយកដ្ឋានសេវនកម្មផ្ទៃក្នុង ប្រធានក្រុមប្រឹក្សានីតិកម្ម ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ប្រធានស្តីទីលេខាធិការដ្ឋាន គ.ជ.ប.ទ ប្រធាននាយកដ្ឋាន អង្គភាពពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ [illegible] ឆ្នាំជូត ទោស័ក ព.ស២៥៦៤

រាជធានីភ្នំពេញ [illegible] ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

<u>កន្លែងទទួល៖</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ដូចប្រការ ៥
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ